សមាគមអាដហុក
ADHOC

# របាយការណ៍

## ស្ថានភាពសិទ្ធិមនុស្ស៖ ឆ្លុះបញ្ចាំងការអនុវត្តសេរីភាពមូលដ្ឋាន ឆ្នាំ២០២៥



ខេត្តបន្ទាយមានជ័យ -សកម្មភាពផ្សព្វផ្សាយអំពីចំណាកស្រុកដោយសុវត្ថិភាព


ភ្នំពេញ - ប្រារព្ធពិធីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារី


ភ្នំពេញ-ទិវានារីអន្តរជាតិ៨មិន(នៅមុខសួនច្បារCDC)

**ភ្នំពេញ ថ្ងៃទី ២៣ ខែមិនា ឆ្នាំ២០២៦**

Address: #3, St 158 Oukhna Trorung Kang, Boeng Raing, Saun Penh, Phnom Penh
Tel: (+855-23) 218 553/210 518/990 544
P.O Box: 1024 – P.O Box 20 at CCC
E-mail: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# មាតិកា

I. **សេចក្ដីផ្ដើម** ........ 3
II. **សិទ្ធិមនុស្ស** ........ 6
១. លំហសេរីភាពមូលដ្ឋាន ........ 7
១.១. សេរីភាពបញ្ចេញមតិ ........ 8
១.២. សេរីភាពបញ្ចេញមតិតាមរយៈការជួបជុំដោយសន្តិវិធី ........ 10
១.៣. សេរីភាពជួបជុំដោសន្តិវិធី៖ ........ 11
២. បាតុកម្ម និង កូដកម្ម៖ ........ 12
៣. ការទទួលបានយុត្តិធម៌តាមរយៈប្រព័ន្ធតុលាការ (ការឃ្លាំមើលសវនាការ) ........ 12
៤. ការគំរាមកំហែង និង ការរើសអើងសកម្មជននយោបាយ ........ 14
៥. ការគំរាមកំហែងសកម្មជនសិទ្ធិមនុស្ស ........ 15
៦. ការធ្វើទារុណកម្ម ........ 16
៧. ការចាប់ឃាត់ខ្លួន និង ការឃុំខ្លួនសកម្មជន៖ ........ 17
III. **សេចក្ដីសន្និដ្ឋាន** ........ 18
IV. **អនុសាសន៍** ........ 19

# I. សេចក្ដីផ្ដើម

សេរីភាពមូលដ្ឋាន[1] គឺជាមូលដ្ឋានគ្រឹះសំខាន់នៃប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ការដាក់កម្រិត ការរឹតត្បិតសេរីភាពមូលដ្ឋាន នាំឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការអនុវត្តសិទ្ធិមនុស្សជាមូលដ្ឋាន[2]។

ផ្អែកលើទិន្នន័យឃ្លាំមើលឆ្នាំ២០២៥ របស់សមាគមអាដហុកបង្ហាញថា ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា មិនមានភាពល្អប្រសើរទេបើធៀបនឹងឆ្នាំ២០២៤ ជាពិសេសបញ្ហាប្រឈមនឹងនិន្នាការរឹតត្បិតលំហរសេរីភាពមូលដ្ឋាន សិទ្ធិនយោបាយនិងបញ្ហាប្រព័ន្ធយុត្តិធម៌។ ការប្រើច្បាប់ព្រហ្មទណ្ឌដើម្បីគ្រប់គ្រងមតិរិះគន់ ការគំរាមកំហែងសកម្មជន និងការប្រើអំពើហិង្សាក្នុងដំណាក់កាលសួរចម្លើយ បង្កឥទ្ធិពលអវិជ្ជមានដល់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ សកម្មភាពនេះ អាចប៉ះពាល់ដល់ កាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា និងទំនុកចិត្តសាធារណៈលើប្រព័ន្ធយុត្តិធម៌ និងដំណើរការលទ្ធិប្រជាធិបតេយ្យ។ ដើម្បីស្តារទំនុកចិត្តសាធារណៈ និងធានាបរិយាកាសប្រកបដោយសេរីភាព និងយុត្តិធម៌ តម្រូវឲ្យមានការកែទម្រង់ជាប្រព័ន្ធ ការអនុវត្តច្បាប់យ៉ាងស្មើភាព និងការគោរពកាតព្វកិច្ចសិទ្ធិមនុស្សតាមរដ្ឋធម្មនុញ្ញ និងស្តង់ដារអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ (ផ្តល់សច្ចាប័ន)។

ក្នុងចំណោមករណីរំលោភសិទ្ធិ និងការរឹតត្បិតសេរីភាពចំនួន ២១៥ ករណីដែលបានរកឃើញ និងចកក្រងដោយសមាគមអាដហុកក្នុងឆ្នាំ២០២៥ គឺមានជនរងគ្រោះ និងអ្នកទទួលរងផលប៉ះពាល់ដោយផ្ទាល់ប្រមាណ ១៥,០៣៩នាក់ (ស្ត្រី ៥០.៣%) ដែលភាគច្រើនជាអ្នកមានជីវភាពក្រីក្រ និងជំពាក់បំណុល។ ការរឹតត្បិតសេរីភាពភាគច្រើនផ្តោតលើសកម្មជននយោបាយ និងសកម្មជនសង្គមរួមមាន អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន សហជីព និងក្រុមយុវជន រួមទាំងអ្នកប្រើប្រាស់បណ្តាញសង្គមក្នុងការបញ្ចេញមតិ។

**និន្នាការរឹតត្បិតសេរីភាពបញ្ចេញមតិ៖** ការប្រើប្រាស់បទ "ញុះញង់" តាមមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា យ៉ាងទូលំទូលាយ ដើម្បីចោទប្រកាន់ និងឃុំខ្លួនបណ្តោះអាសន្នបុគ្គលដែលបញ្ចេញមតិរិះគន់តាមបណ្តាញសង្គម ដោយមិនមានភស្តុតាងច្បាស់លាស់បញ្ជាក់ពី "ហានិភ័យជាក់ស្តែងនឹងអាចកើតមានអំពើហិង្សា ឬបទឧក្រិដ្ឋដែលប៉ះពាល់ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈជិតមកដល់" ដែលមិនឆ្លើយតបនឹងគោលការណ៍សមាមាត្រ និងភាពចាំបាច់។

ការដោះលែងដោយសារមានការសុំទោសជាសាធារណៈ ឬបញ្ឈប់សកម្មភាពរិះគន់ អាចបង្កឥទ្ធិពលភ័យខ្លាចនៅក្នុងសង្គមដែលផ្ទុយស្មារតីច្បាប់ " សិទ្ធិមិនត្រូវបង្ខំឲ្យសារភាព ឬធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង " ដូចមានចែងក្នុងមាត្រា៣២១ កឋាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៤(3-g) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

ការអនុវត្តដាក់កម្រិតនិន្នាការរឹតត្បិតសេរីភាពបញ្ចេញមតិ មានហានិភ័យផ្ទុយស្មារតីច្បាប់ ដែលធានាសិទ្ធិសេរីភាពបញ្ចេញមតិដូចមានចែងក្នុង មាត្រា៤១នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា១៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា១៩នៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស។

---

[1] សេរីភាពមូលដ្ឋានរួមមាន៖ សេរីភាពបញ្ចេញមតិ សេរីភាពជួបជុំដោយសន្តិវិធី និងសេរីភាពសមាគមន៍

[2] សិទ្ធមនុស្សជាមូលដ្ឋានរួមមាន៖ សិទ្ធិពលរដ្ឋ សិទ្ធិមនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌

**ការរឹតត្បិតសេរីភាពជួបជុំដោយសន្តិវិធី៖** ៧៥% នៃសកម្មភាពផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល ត្រូវបានអាជ្ញាធរមូលដ្ឋានរារាំង ឬឃ្លាំមើលយ៉ាងតឹងរ៉ឹង ដូចជា ការទាមទាររកលិខិតអនុញ្ញាត្ត/លិខិតជូនដំណឹង ការថតចម្លងបញ្ជីវត្តមានអ្នកចូលរួម ការថតរូបគ្មានការអនុញ្ញាត្ត និងចុះសួរនាំដល់ផ្ទះអ្នកចូលរួម។ ការអនុវត្តបែបនេះ គឺជាការជ្រៀតជ្រែកលើសិទ្ធិឯកជន និងសេរីភាពជួបជុំដោយសន្តិវិធី ដែលផ្ទុយស្មារតីច្បាប់ធានាសេរីភាពជួបជុំដោយសន្តិវិធី ដូចមានចែងៈ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា២១នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា២០នៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ព្រមទាំងសេចក្តីជូនដំណឹងលេខ២០០៦ស.ជ.ណ ចុះថ្ងៃទី២៧ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ។

ក្នុងសកម្មភាពជួបជុំដោយសន្តិវិធីចំនួន ៤៥ករណី (អ្នកចូលរួម៥,០៩២ នាក់) ដែលបានកត់ត្រា គឺមានចំនួនអាជ្ញាធរ និងកងកម្លាំងតាមឃ្លាំមើលប្រហែល ៨០% នៃចំនួនអ្នកចូលរួមសរុប ដែលការនេះអាចបង្កបរិយាកាសភ័យខ្លាច ជំនួសឲ្យតួនាទីការពារ និងសម្របសម្រួល។

**បាតុកម្ម និងកូដកម្ម៖** ការធ្វើបាតុកម្ម និងកូដកម្មរបស់សហជីព ភាគច្រើនមានលក្ខណៈសន្តិវិធី ដែលធានាដោយច្បាប់ព្រះរាជាណាចក្រកម្ពុជាៈ មាត្រា៣៧នៃរដ្ឋធម្មនុញ្ញ មាត្រា៣១៨នៃច្បាប់ការងារ និងមាត្រា៤នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ព្រមទាំងច្បាប់អន្តរជាតិៈ មាត្រា២១ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ផ្ទុយមកវិញ ចំពោះសកម្មភាពឈរឃ្លាំមើលព្រោងព្រាតរបស់អាជ្ញាធរ អាចបង្កឥទ្ធិពលបំបាក់ស្មារតីអ្នកចូលរួម និងបង្កបរិយាកាសគំរាមកំហែងដល់សិទ្ធិសេរីភាព ជាជាងប្រើតួនាទីក្នុងគោលបំណងការពារ និង សម្របសម្រួល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈពិតប្រាកដ។

**បញ្ហាប្រព័ន្ធយុត្តិធម៌ និងការទទួលបានយុត្តិធម៌(តាមរយៈការឃ្លាំមើលសវនាការ)៖** ទិន្នន័យបានបង្ហាញពីការខ្វះជំនឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌ ដែល៩២% នៃជនរងគ្រោះមិនដាក់ពាក្យបណ្តឹង ដោយសារខ្វះទំនុកចិត្ត ភ័យខ្លាច និងការពិបាកនៃនីតិវិធីតុលាការ។

មានករណីឃុំខ្លួនបណ្តោះអាសន្នលើសកំណត់ និងការលើកពេលសវនាការដោយមិនកំណត់ថ្ងៃច្បាស់លាស់។ ការយឺតយ៉ាវជាបន្តបន្ទាប់ក្នុងការចាប់ផ្តើមសវនាការ( ទិន្នន័យ៩៨%) និងការបង្កផលលំបាកមេធាវីក្នុងការទទួលបានសំណុំរឿង ប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ការការពារក្តីដោយប្រសិទ្ធិភាពនិងឆាប់រហ័ស។

ការអនុវត្តសកម្មភាពនេះ ប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិទទួលបានយុត្តិធម៌ ធានាដោយ កាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា១៤(3b-c) សិទ្ធិជំនុំជម្រះដោយឆាប់រហ័ស និងសិទ្ធិមេធាវីក្នុងការចូលប្រើសំណុំរឿង និងមាត្រា ៩ ការឃុំខ្លួនដោយបំពាន។

**ការគំរាមកំហែង និងការប្រើប្រាស់យន្តការរដ្ឋក្នុងបរិបទនយោបាយ៖** ទិន្នន័យការគំរាមកំហែង និងការរើសអើងសកម្មជននយោបាយ មានចំនួន ៣៥ករណី ដែលមាកលក្ខណៈស្រដៀងគ្នាដូចជា ការអញ្ជើញសកម្មជនទៅជួប និងដាក់សម្ពាធបង្ខំឲ្យលាលែងពីគណបក្ស ឬចូលរួមជាមួយគណបក្សផ្សេង (ផ្លាស់ប្តូរគណបក្ស)។ ការប្រើប្រាស់បទចោទព្រហ្មទណ្ឌជាឧបករណ៍បង្កការភ័យខ្លាច ជាមធ្យោបាយដាក់សម្ពាធ និងការដាក់លក្ខខណ្ឌនយោបាយក្នុងការដោះលែង អាចប៉ះពាល់ដល់សេរីភាពសមាគម និងសិទ្ធិនយោបាយ ផ្ទុយគោលការណ៍នីតិរដ្ឋ និងឯករាជ្យភាពអាជ្ញាធរ ដូចមានចែងក្នុងច្បាប់ព្រះរាជាណាចក្រកម្ពុជាៈ រដ្ឋធម្មនុញ្ញមាត្រា៣៥ ធានាសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ និងមាត្រា៤២សិទ្ធិបង្កើតសមាគម និង

គណបក្សនយោបាយនិងច្បាប់អន្តរជាតិៈ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ មាត្រា២២ សេរីភាពសមាគមនិងការចូលរួមនយោបាយ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២០ សិទ្ធិសមាគម និងជួបជុំដោយសន្តិវិធី។

**ការធ្វើទារុណកម្ម និងការបង្ខំឲ្យសារភាព៖** ទិន្នន័យធ្វើទារុណកម្មមានចំនួន២៦ករណី ក្នុងអំឡុងសួរចម្លើយ ដោយប្រើអំពើហិង្សាបង្ខំឲ្យសារភាព និងផ្តិតមេដៃលើកំណត់ហេតុ។

ការអនុវត្តបែបនេះ ផ្ទុយស្មារតីរដ្ឋធម្មនុញ្ញ ព្រះរាជណាចក្រកម្ពុជា មាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣២១ អនុសញ្ញាប្រឆាំងទារុណកម្ម មាត្រា២ និងមាត្រា១៥ និងមាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ លើសពីនេះទៀត ការភ័យខ្លាចមិនហ៊ានដាក់ពាក្យបណ្តឹងរបស់ជនរងគ្រោះ បង្ហាញពីបញ្ហាឯករាជ្យភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ចាប់ពីដំណាក់កាលនគរបាលយុត្តិធម៌ និងការការពារសាក្សី។




## II. សិទ្ធិមនុស្ស

ឆ្នាំ២០២៥ សមាគមអាដហុកបានធ្វើការឃ្លាំមើល-អង្កេតអន្តរាគមន៍ ករណីរំលោភសិទ្ធិមនុស្ស និងរឹតត្បិតសេរីភាព ចំនួន**២១៥ករណី** បានកើតឡើងនៅតាមខេត្តគោលដៅទូទាំងប្រទេស។ ជាពិសេស ករណីសេរីភាពមូលដ្ឋាននៅតែបន្តរឹតត្បិតនិងរំលោភបំពានដូចជា៖ សេរីភាពជួបជុំដោយសន្តិវិធី ៤៥ករណី មានកម្លាំងអាជ្ញាធរមានសមត្ថកិច្ច ឃ្លាំមើលជុំវិញសកម្មភាពជួបជុំ ប្រហែល៨០% នៃចំនួនអ្នកចូលរួមធ្វើការជួបជុំសរុបចំនួន(៥,០៩២នាក់)។

ក្នុងចំណោម២១៥ករណី ប៉ះពាល់ដល់ជនរងគ្រោះដោយផ្ទាល់ចំនួន១៥,០៣៩នាក់(ស្ត្រី៥០.៣%)។ ៧៥%ជាជនរងគ្រោះមានជីវភាពក្រីក្រ(៤៩.៣%ជំពាក់បំណុល) និង២៥% ជីវភាពមធ្យម។

ក្នុងចំណោម ២១៥ករណី មានត្រឹមតែ ៨% (១៨ករណី) ប៉ុណ្ណោះ ដែលបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ខណៈ៩២%(១៩៥ករណី) មិនដាក់ពាក្យបណ្តឹង ដោយមូលហេតុធំៗបីគឺ៖

1. ៥២%(១០២ករណី) អត់មានជំនឿលើអាជ្ញាធរក្នុងការរកដំណោះស្រាយ

2. ២០%(៣៨ករណី) មិនចង់មានរឿងវែងឆ្ងាយជាពិសេសជាមួយនីតិវិធីតុលាការបច្ចុប្បន្ន
3. ២៨%(៥៥ករណី) ភ័យខ្លាចការគម្រាមកំហែងពីភាគីពាក់ព័ន្ធមានអំណាចនិងមានទ្រព្យធន

ទិន្នន័យ ការខ្វះជំនឿលើអាជ្ញាធរ និងមិនចង់មានរឿងជាមួយនីតិវិធីតុលាការ បានបង្ហាញពីបញ្ហាឯករាជ្យភាពប្រព័ន្ធយុត្តិធម៌ និងប្រសិទ្ធភាពដោះស្រាយរបស់អាជ្ញាធរ និងតុលាការ។

៦៦%(១៤០ករណី)សមាគមអាដហុក បានអន្តរាគមន៍តាមរយៈការដាក់លិខិតទៅស្ថាប័នពាក់ព័ន្ធ ការជួបផ្ទាល់ជាមួយសមត្ថកិច្ច ការបញ្ចេញមតិតាមប្រព័ន្ធផ្សព្វផ្សាយ ការចេញសេចក្តីថ្លែងការណ៍ និងការផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់។

**មូលហេតុនាំឲ្យកើតមានការរឹតត្បិត-ការរំលោភសិទ្ធិសេរីភាព៖** គឺភាគច្រើនបណ្តាលមកពីជនប្រព្រឹត្តមានគោលបំណងគម្រាមកំហែងដើម្បីបំបាក់ស្មារតីជនរងគ្រោះ បើយោងតាមរបាយការណ៍បានបង្ហាញថាមាន ៤៤%នៃ២១៥ករណី ជនរងគ្រោះត្រូវបានគម្រាមកំហែងបំបាក់ស្មារតី - ២៤% អាងអំណាចតួនាទី - ១៧%និន្នាការនយោបាយ និង១៥%បណ្តាលមកពីនិយាយរិះគុណរដ្ឋាភិបាល និងបង្ខំឲ្យទទួលយកដំណោះស្រាយ។

**ស្ថានភាពអ្នករងគ្រោះ៖** អ្នករងគ្រោះក្នុងករណីរឹតត្បិត-រំលោភសិទ្ធិសេរីភាព ភាគច្រើនជាសកម្មជននយោបាយនិងជាសកម្មជនដែលធ្វើការដើម្បីផលប្រយោជន៍សង្គមដូចជាៈ អ្នកការពារសិទ្ធិមនុស្ស សកម្មជនដីធ្លី សកម្មជនព្រៃឈើ សកម្មជនបរិស្ថាន បុគ្គលិកសហជិព បុគ្គលិកអង្គការសង្គមស៊ីវិល តំណាងសហគមន៍ និងអ្នកសារព័ត៌មាន។ យោងតាមរបាយការណ៍នៅក្នុងអំឡុងឆ្នាំ២០២៥ មានជនរងគ្រោះ ចំនួន០៤នាក់បានស្លាប់បាត់បង់ជីវិតស្ថិតនៅបណ្តារខេត្តផ្សេងគ្នា " ១. ខេត្តបន្ទាយមានជ័យៈ ម្នាក់ស្លាប់ក្រោយបញ្ជូនពីពន្ធនាគារខេត្តបន្ទាយមានជ័យ ទៅមន្ទីរពេទ្យមិត្តភាព កម្ពុជា-ជប៉ុនស្រុកមង្គលបុរី "ករណីកាន់កាប់-ដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត និងបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស", ២. ខេត្តព្រះសីហនុៈ ម្នាក់ស្លាប់ក្នុងករណីហឹង្សាបំផ្លាញទ្រព្យសម្បត្តិនិងដុតបំផ្លាញផ្ទះដោយមនុស្សមួយក្រុមនៅខេត្តព្រះសីហនុ, ៣. ខេត្តព្រៃវែងៈ ម្នាក់ស្លាប់ករណីហឹង្សាដោយមនុស្សមួយក្រុមនៅខេត្តព្រៃវែង, និង៤.ខេត្ត កំពង់ស្ពឺៈ ម្នាក់ស្លាប់ក្នុងករណីនាយប៉ុស្តិ៍រដ្ឋបាលឃុំពោធិអង្គ្រងប្រើកាំភ្លើងAKបាញ់ចំដោះខាងឆ្វេង ធ្លាក់ទឹកប្រឡាយនៅខេត្តកំពង់ស្ពឺ" និង ជនរងគ្រោះ២៨%(៦០នាក់) ត្រូវបានចាប់ឃុំខ្លួនបណ្តោះអាសន្ន ព្រមទាំងដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ០៤នាក់ និងកាត់ទោសដាក់ព័ន្ធនាគារ០២នាក់ ជាមួយគ្នានេះក៏មានអ្នករងគ្រោះ៤២%(៩០នាក់) បាននឹងកំពុងទទួលរងនូវការភ័យខ្លាចអំពីសុវត្ថិភាពសន្តិសុខផងដែរ ។

**ស្ថានភាពអ្នកប្រព្រឹត្ត៖** អ្នកប្រព្រឹត្តក្នុងករណីរឹតត្បិត និង រំលោភសិទ្ធិសេរីភាព ភាគច្រើនគឺជាអាជ្ញាធរមានសមត្ថកិច្ចនៅតាមមូលដ្ឋានក្នុងនោះរួមមានៈ កងកម្លាំងនគរបាល កងរាជអាវុធហត្ថ យោធា អាជ្ញាធរស៊ីវិលនិងមួយចំនួនតូចជា ប្រជាពលរដ្ឋដែលធ្វើតាមបញ្ជារអ្នកមានអំណាច ឬអ្នកមានទ្រព្យ។ យោងតាមរបាយការណ៍ក្នុងឆ្នាំ២០២៥ មានជនប្រព្រឹត្តត្រឹមតែ០៤នាក់ប៉ុណ្ណោះ ត្រូវបានចាប់-ឃុំខ្លួនបណ្តោះអាសន្ន ០១នាក់បានគេចខ្លួន និង០២នាក់ផ្សេងទៀតទទួលពិន័យរដ្ឋបាល។

**១. លំហសេរីភាពមូលដ្ឋាន**

សេរីភាពមូលដ្ឋាន គឺជាឆ្អឹងខ្នងសំខាន់សំរាប់តម្រង់ទិសការអនុវត្ត សិទ្ធិមនុស្សជាមូលដ្ឋាន ក្នុងដំណើរការលើកកម្ពស់គោរពការពារ លទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ជាពិសេស សេរីភាពខាងបញ្ចេញមតិ និងសេរីភាពខាងជួបជុំដោយសន្តិវិធី។

## ១.១. សេរីភាពបញ្ចេញមតិ

របាយការណ៍បង្ហាញថាមាន ៣២ករណីរឹតត្បិតសេរីភាពបញ្ចេញមតិ ដែលក្នុងនោះ ៥៩%(១៩ករណី) ត្រូវបានចាប់ឃុំខ្លួនបណ្ដោះអាសន្នក្រោមបទ "ញុះញង់" តាមមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីការបញ្ចេញមតិតាមបណ្ដាញសង្គម។ ភាគច្រើនជាយុវជន "សិស្សមធ្យមសិក្សា និង និស្សិតបរិញ្ញាបត្រ" ហើយយុវជនទាំងនោះគឺជាសាច់ញាតិរបស់សកម្មជននយោបាយ និងជាសកម្មជនដែលសកម្មក្នុងរឿងសង្គម។ ករណីមិនឃុំខ្លួនបណ្ដោះអាសន្ន ក៏បង្កផលប៉ះពាល់ផ្លូវចិត្តដូចជា ភ័យខ្លាច បាក់ស្មារតី និង រត់គេចខ្លួន។ ជាពិសេសករណី៖

1. ភ្នំពេញ៖ នៅថ្ងៃទី៣០-ឧសភា-២០២៥ លោក អ.ស និស្សិតឆ្នាំទី៤ផ្នែកគណនេយ្យ និងជាបុគ្គលិកក្រុមហ៊ុន ត្រូវបានចាប់ខ្លួនយកទៅសាកសួរនៅស្នងការដ្ឋានរាជធានីភ្នំពេញ បន្ទាប់ពីគាត់បានសរសេរបញ្ចេញយោបល់រិះគន់តាមបណ្ដាញសង្គម បន្ទាប់មកបញ្ជូនទៅឃុំខ្លួន ពន្ធនាគារម១ព្រៃសរដោយចោទពីបទញុះញង់ឲ្យមានបទឧក្រិដ្ឋជាអាទិ៍។ ការបញ្ចេញមតិរិះគន់រដ្ឋាភិបាល ជាទូទៅត្រូវបានការពារដោយសេរីភាពបញ្ចេញមតិ លុះត្រាតែមានភស្តុតាងច្បាស់ថាបង្ក"ហានិភ័យជាក់ស្ដែងនិងជិតមកដល់" នៃអំពើហិង្សា ឬបទឧក្រិដ្ឋ។
2. ខេត្តកណ្ដាល៖ នៅថ្ងៃទី២៧-មិនា-២០២៥ លោក ស.ល.រ រស់នៅក្រុងតាខ្មៅ ត្រូវបានចាប់ខ្លួនបន្ទាប់មកបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ននៅព័ន្ធនាគារ ពីបទញុះញង់បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរ ដល់សន្តិសុខសង្គម ក្រោយពីលោកបានបង្ហោះសារតាមបណ្ដាញសង្គម រិះគន់រដ្ឋាភិបាលអំពីបញ្ហាគ្រឿងស្រវឹងគ្រឿងញៀន។ ៣ថ្ងៃក្រោយមកលោកត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌបន្ទាប់ពីបានធ្វើវីដេអូឡាយសុំទោសថ្នាក់ដឹកនាំពីក្នុងព័ន្ធនាគារ។ លក្ខខណ្ឌ "សុំទោសជាសាធារណៈ" ពីក្នុងពន្ធនាគារ អាចមានសំណួរថាតើការសុំទោសនោះចេញពីការស្ម័គ្រចិត្តដោយពិតប្រាកដ ឬជាការដាក់សម្ពាធ? ករណីនេះអាចប៉ះពាល់ដល់សិទ្ធិមិនត្រូវបង្ខំឲ្យសារភាព ឬសកម្មភាពប្រឆាំងខ្លួនឯង។
3. ខេត្តបន្ទាយមានជ័យ៖ នៅថ្ងៃទី១៤-មិថុនា-២០២៥ ព្រះសង្ឃ ថ.វ.គ វត្តស្លក្រាម ត្រូវបានចាប់បន្ទាប់ពីព្រះអង្គបានបញ្ចេញមតិយោបល់តាមបណ្ដាញសង្គម។ ព្រះអង្គត្រូវបានអនុគុណ ស្រុកស្វាយចេកផ្សឹកហើយបញ្ជូនមកឃុំខ្លួននៅព័ន្ធនាគារព្រៃសររាជធានីភ្នំពេញ។ ករណីនេះប៉ះពាល់ទាំងសេរីភាពបញ្ចេញមតិ និងសេរីភាពសាសនា។ ជាពិសេសសំណួរសួរថាតើការផ្សឹកជាមុននឹងដំណើរការតុលាការ អាចប៉ះពាល់ដល់សិទ្ធិនីតិវិធីត្រឹមត្រូវដែរឬទេ?
4. ខេត្តសៀមរាប៖ នៅថ្ងៃទី១៤-តុលា-២០២៥ លោក ព.ប ត្រូវបានចាប់ខ្លួនបញ្ជូនមកឃុំខ្លួននៅពន្ធនាគារម១ព្រៃសររាជធានីភ្នំពេញដោយចោទប្រកាន់ពីបទរួមគំនិតក្បត់ធ្វើសកម្មភាពតាមទូរគមនាគមន៍និងប្រព័ន្ធ ទំនាក់ទំនងសង្គម ហ្វេសប៊ុកកបង្ហោះ ករណីបាតុកម្មនៅប្រទេសនេប៉ាល។ ការបង្ហោះព័ត៌មានអំពីព្រឹត្តិការណ៍ អន្តរជាតិ គួរត្រូវបានការពារ លុះត្រាតែបង្ហាញចេតនាច្បាស់ក្នុងការបង្កគ្រោះថ្នាក់សន្តិសុខជាតិ។
5. ខេត្តតាកែវ៖ លោក ភ.យ មានវ័យ៤១ឆ្នាំ ជាជនពិការស្វិតជើងពីកំណើត រស់នៅភូមិត្រពាំងឈូក ឃុំត្រឡាចស្រុកទ្រាំងខេត្តតាកែវ ដែលត្រូវបានចាប់និងឃុំខ្លួនចំនួន៣លើកគឺ៖ (ចាប់ខ្លួនលើកទី៣) នៅថ្ងៃទី២៩-តុលា-២០២៥ បានឃុំខ្លួននៅព័ន្ធនាគារខេត្តតាកែវ ពីបទញុះញង់ឲ្យមានបទឧក្រិដ្ឋជាអាទិ៍ បន្ទាប់ពីលោកបានធ្វើសកម្មភាពបញ្ចេញមតិ នៅតាមបណ្ដាញសង្គមរិះគុណរដ្ឋាភិបាល ។ (ចាប់ខ្លួនលើកទី២-ខេត្តតាកែវ) នៅថ្ងៃទី ១៩ ខែមិនា ឆ្នាំ២០២៤ បានផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារ១៨ខែពីបទញុះញង់ឲ្យមានការរើសអើង បន្ទាប់ពីបង្ហោះសារលើហ្វេសប៊ុកផ្ទាល់ខ្លួនដែលមានអត្ថន័យរិះគុណ ខ្លាំងៗដល់ថ្នាក់ដឹកនាំរដ្ឋាភិបាល។ (ចាប់ខ្លួនលើកទី១-ខេត្តតាកែវ) ជាប់ពន្ធនាគារចំនួន០៥ខែនៅក្នុងឆ្នាំ២០១៩ ពាក់ព័ន្ធនឹងបទចោទប្រកាន់"ញុះញង់និងជេរប្រមាថជាសាធារណៈ"ទាក់ទងលោករិះគន់ភាពអសកម្មរដ្ឋាភិបាល។ ការចាប់ខ្លួនជាបន្តបន្ទាប់ ចំពោះមតិរិះគន់បង្ហាញពីហានិភ័យនៃការប្រើច្បាប់ព្រហ្មទណ្ឌជាឧបករណ៍បង្ក្រាបសេរីភាពបញ្ចេញមតិ។

**តាមការវិភាគ៖**

- ការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះករណីបញ្ចេញមតិតាមបណ្ដាញសង្គម (តាមហ្វេសប៊ុក) មិនមានភាពចាំបាច់ទេ ករណីមិនមានតម្រុយជាក់ស្ដែងថា ការបញ្ចេញមតិនោះ អាចបង្កឲ្យមានហានិភ័យកើតមានឡើង អំពើហិង្សា ឬបទឧក្រិដ្ឋ។
- លក្ខខណ្ឌនៃការសុំទោសជាសាធារណៈ ជាពិសេសធ្វើនៅក្នុងពន្ធនាគារ អាចប៉ះពាល់ដល់សិទ្ធិមិនត្រូវបង្ខំឲ្យសារភាព ឬសក្ខីកម្មប្រឆាំងខ្លួនឯង ដែលមតិសាធារណៈជនភាគច្រើនយល់ឃើញថា ជាការដាក់សម្ពាធច្រើនជាងចេញពីឆន្ទៈស្ម័គ្រចិត្តពិតប្រាកដ។
- ការប្រើបទរួមគំនិតក្បត់ ចំពោះការបញ្ចេញមតិបង្ហោះព័ត៌មានតាមបណ្ដាញសង្គម ធ្វើឲ្យបរិយាកាសសិទ្ធិសេរីភាពបញ្ចេញមតិកាន់តែរួមតូច និង រឹតត្បិតខ្លាំង ដែលបង្កឥទ្ធិពលការភ័យខ្លាចនៅក្នុងសង្គម។

ទិន្នន័យបានបង្ហាញនិន្នាការប្រើបទ "ញុះញង់" យ៉ាងទូលំទូលាយចំពោះការបញ្ចេញមតិតាមបណ្ដាញសង្គម (ហ្វេសប៊ុក) ដោយគ្មានភស្តុតាងច្បាស់លាស់ បញ្ជាក់ពីហានិភ័យជាក់ស្ដែង ដែលអាចនាំឲ្យមានអំពើហិង្សា ឬបទឧក្រិដ្ឋ ហើយគ្មានភាពចាំបាច់ និងមិនសមាមាត្រទៅនិងអំពើ អាចផ្ទុយស្មារតីច្បាប់ជាតិ-អន្តរជាតិជាធរមានដូចជា៖ មាត្រា៤១ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានធានាសិទ្ធិសេរីភាពបញ្ចេញមតិ ជួបជុំ និងសមាគម,មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា១៩ នៃសេចក្ដីប្រកាសជា សកលស្ដីពីសិទ្ធិមនុស្ស ធានាសេរីភាពបញ្ចេញមតិ និងអនុសាសន៍លេខ៣៤ របស់គណកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

ដើម្បីធានាបរិយាកាសសុវត្ថិភាពសេរីភាពបញ្ចេញមតិ ដោយសន្តិវិធីជាពិសេសចមពោះយុវជន និងសកម្មជនសង្គម គួរតែកែសម្រួល និងអនុវត្ត មាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌឲ្យតឹងរឹងពិនិត្យហ្មត់ចត់ តាមគោលការណ៍ភាពចាំបាច់ និងសមាមាត្រ។ លើសពីនេះ ការចាប់ឃុំខ្លួនបណ្ដោះអាសន្នគួរត្រូវបានប្រើជាជម្រើសចុងក្រោយ។

## ១.២. សេរីភាពបញ្ចេញមតិតាមរយៈការជួបជុំដោយសន្តិវិធី



ខេត្តព្រះវិហារ - ថ្ងៃទី២៣-សីហា-ឆ្នាំ២០២៥(ធ្វើការផ្សព្វផ្សាយនៅក្នុងផ្ទះប្រជាពលរដ្ឋ)

របាយការណ៍ឆ្នាំ២០២៥[3] សកម្មភាពផ្សព្វផ្សាយអំពីប្រជាធិបតេយ្យ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានចំនួន៨១វគ្គ។ ក្នុងនោះ ៧៥% (៦១វគ្គ) នៃ៨១វគ្គ ត្រូវបានអាជ្ញាធរមូលដ្ឋាន[4] រឹតត្បិត និងអនុវត្តសកម្មភាពដែលប៉ះពាល់ដល់សិទ្ធិសេរីភាពបញ្ចេញមតិតាមរយៈការជួបជុំដោយសន្តិវិធី ក្នុងចំណោមនោះមាន៖

- អាជ្ញាធរមូលដ្ឋានបានសួរនាំព័ត៌មាន មុនពេល និងក្រោយពេលសកម្មភាពផ្សព្វផ្សាយ
- អាជ្ញាធរមូលដ្ឋាន ចុះមករារាំង-សួររកលិខិតអនុញ្ញាត្ត ឲ្យធ្វើសកម្មភាពផ្សព្វផ្សាយ ដោយបានបញ្ជាក់ថា "ត្រូវតែស្នើសុំការអនុញ្ញាត្ត មុនពេលធ្វើសកម្មភាពផ្សព្វផ្សាយ"។
- អាជ្ញាធរតម្រូវឲ្យជូនដំណឹងជាមុន
- អាជ្ញាធរឃ្លាំមើល ថតរូប ថតវីដេអូ និងស្នើសុំបញ្ជីវត្តមាន ដែលក្នុងនោះបញ្ជាក់អត្តសញ្ញាណ អ្នកចូលរួមដូចជា ឈ្មោះ លេខទូរស័ព្ទ អាស័យដ្ឋានជាដើម។
- ចូលទៅអង្គុយសង្កេតការណ៍នៅក្នុងវគ្គផ្សព្វផ្សាយរហូតដល់ចប់
- ចុះទៅដល់ផ្ទះអ្នកចូលរួម សួរនាំ ឬគំរាមកំហែង
- ពេលខ្លះហាមឃាត់ប្រជាពលរដ្ឋមិនឲ្យចូលរួមទៀតផង

សកម្មភាពទាំងនេះ បានបង្ករបរិយាកាសភ័យខ្លាច និងប៉ះពាល់ដល់ស្មារតីអ្នកចូលរួម ជាពិសេសអ្នកចូលរួមការភ័យខ្លាចថានឹងត្រូវបានវាយតម្លៃអវិជ្ជមានពីអាជ្ញាធរ។ ការហាមឃាត់ប្រជាពលរដ្ឋមិនឲ្យចូលរួមជួបជុំដោយសន្តិវិធីអាចជាការរឹតត្បិតមិនសមស្រប និងការគំរាមកំហែង-ការចុះសួរនាំដលើផ្ទះអ្នកចូលរួមក្រោយសកម្មភាព ការថតរូប ស្នើបញ្ជីវត្តមាន អង្គុយតក់ត្រាប្រមូលព័ត៌មានអត្តសញ្ញាណ អាចចាត់ទុកថាជាការជ្រៀតជ្រែកលើសិទ្ធិឯកជនភាព សន្តិសុខផ្ទាល់ខ្លួន និងបង្កឥទ្ធិពលភ័យខ្លាច ដែលផ្ទុយនឹងស្មារតីរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា៤១ ធានាសិទ្ធិសេរីភាពបញ្ចេញមតិ

[3] ឆ្នាំ២០២៥ បាយការណ៍សកម្មភាពផ្សព្វផ្សាយអំពីប្រជាធិបតេយ្យ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដល់ប្រជាពលរដ្ឋ ស្ថិតនៅក្នុងសហគមន៍គោលដៅ: ៨១ភូមិ ៤៩ឃុំ/សង្កាត់ ២៦ស្រុក/ខណ្ឌ នៃ១៦ខេត្តគោលដៅ ដែលមានអ្នកចូលរួមសរុប ២,៤៣០នាក់ (ស្ត្រី១,៧៩០) ជនជាតិដើមភាគតិចចំនួន៥៣២នាក់។ សកម្មភាពនេះបានធ្វើនៅក្នុង ១៦ខេត្តគោលដៅ ដែលសមាគមអាហុកមានស្នាកការ៖ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តកំពង់ឆ្នាំង ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តមណ្ឌលគីរី ខេត្តរតនគីរី ខេត្តស្ទឹងត្រែង ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តកណ្តាល។

[4] ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំសង្កាត់ នគរបាលរដ្ឋបាលប៉ុស្តិ៍ មេភូមិ អនុភូមិ ប្រជាការពារភូមិ-សន្តិសុខភូមិ

ការជួបជុំ និងការបង្កើតសមាគម។ មាត្រា១៩ ធានាសេរីភាពបញ្ចេញមតិ និងមាត្រា២១ សេរីភាពជួបជុំដោយសន្តិវិធី នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ និងអនុសាសន៍លេខ៣៧ គណកម្មាការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អនុម័តថ្ងៃទី២៧-កក្កដា-២០២០ ក្នុងសម័យប្រជុំលើកទី១២៩។

អាជ្ញាធរតម្រូវឲ្យស្នើសុំការអនុញ្ញាត្ត "សួររកលិខិតអនុញ្ញា" ឬតម្រូវឲ្យជូនដំណឹងជាមុន គឺជាសកម្មភាពផ្ទុយនឹង សេចក្តីជូនដំណឹងក្រសួងមហាផ្ទៃ លេខ២០០៦ស.ជ.ណ ចុះថ្ងៃទី២៧ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការធ្វើសកម្មភាពរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅតាមមូលដ្ឋាន មានសិទ្ធិសេរីភាពពេញលេញ ក្នុងការធ្វើសកម្មភាពដោយពុំចាំបាច់ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានឡើយ។

ផ្អែកលើទិន្នន័យ ៧៥% នៃសកម្មភាពផ្សព្វផ្សាយត្រូវបានរឹតត្បិត បានបង្ហាញពីបញ្ហាប្រព័ន្ធក្នុងការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិតាមរយៈការជួបជុំដោយសន្តិវិធី។

## ១.៣. សេរីភាពជួបជុំដោសន្តិវិធី៖

អាដហុក បានឃ្លាំមើលសកម្មភាពជួបជុំដោយសន្តិវិធីចំនួន៤៥ករណី ដែលមានអ្នកចូលរួមសរុបចំនួន ៥,០៩២ នាក់ (ស្ត្រី ២,៣៣៤ នាក់)។ ក្នុងនោះអាជ្ញាធរចំនួនប្រហែល ៤,០៧៤ នាក់ (ស្មើ៨0%នៃចំនួនអ្នកចូលរួមសរុប) មានវត្តមានឃ្លាំមើលជុំវិញទីតាំងចាប់ពីដើមរហូតដល់ចប់។ លើសពីនេះទៀត មាន១៣%(០៦ករណី) ត្រូវបានអាជ្ញាធរមូលដ្ឋានរារាំងសួររកលិខិតអនុញ្ញាត សួររកបញ្ជីវត្តមានអ្នកចូលរួម ថតរូបកត់ត្រាអត្តសញ្ញាណ និងអង្គុយសង្កេតការណ៍ ក្នុងវគ្គបណ្តុះបណ្តាលរហូតដល់ចប់។ ការជួបជុំត្រូវបានធ្វើឡើងដោយសកម្មជនដីធ្លី សកម្មជនព្រៃឈើ សកម្មជនបរិស្ថាន សកម្មជនសិទ្ធិមនុស្ស សមាគមគ្រូបង្រៀន សហជិពនៅក្នុងគោលបំណងប្រយោជន៍រួមគឺ ទិវារំលឹកខួប-ផ្សព្វផ្សាយព័ត៌មាន-បង្កើនចំណេះដឹងជាដើម។

អនុសាសន៍លេខ៣៧ គណកម្មាការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អនុម័តថ្ងៃទី២៧-កក្កដា-២០២០ ក្នុងសម័យប្រជុំលើកទី១២៩ ដែលផ្តោតសំខាន់ចំពោះកាតព្វកិច្ចរបស់រដ្ឋតាមមាត្រា២១សិទ្ធិជួបជុំដោយសន្តិវិធីនៃតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានបញ្ជាក់ជាស្មារតីអំពីៈ វត្តមានអាជ្ញាធរត្រូវមានគោលបំណងការពារ មិនមែនបង្ករភាពភ័យខ្លាច រដ្ឋមានកាតព្វកិច្ចវិជ្ជមានក្នុងការសម្របសម្រួល និងធានាសុវត្ថិភាពការជួបជុំ ហើយការប្រមូលព័ត៌មានអត្តសញ្ញាណអ្នកចូលរួម ត្រូវមានមូលដ្ឋាច្បាប់ច្បាស់លាស់និងការការពារទិន្នន័យ។

វត្តមានអាជ្ញាធរក្នុងការជួបជុំដោយសន្តិវិធី ត្រូវតែអនុវត្តតាមគោរពគោលការណ៍ៈ មិនជ្រៀតជ្រែកលើខ្លឹមសារ មិនបង្កបរិយាកាស ការរឹតត្បិត-ការគំរាមកំហែង និងមិនរំលោភសិទ្ធិឯកជនភាព។ ដូច្នេះ ការថតរូប ប្រមូលបញ្ជីវត្តមាន និងអង្គុយសង្កេតការណ៍ដោយគ្មានមូលហេតុជាក់ស្តែងទាក់ទងនឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈពិតប្រាកដ អាចប៉ះពាល់ដល់សិទ្ធិឯកជន និងបង្ករឲ្យមានឥទ្ធិពលការភ័យខ្លាច ដែលធ្វើឲ្យប្រជាពលរដ្ឋខ្លាចក្នុងការចូលរួមសកម្មភាពសាធារណៈ ជាពិសេសបង្ហាញពីហានិភ័យនៃការរឹតត្បិតសេរីភាពជួបជុំ ដែលអាចប៉ះពាល់ដល់ការអនុវត្តសិទ្ធិមនុស្សក្នុងសង្គមប្រជាធិបតេយ្យ។ ផ្ទុយស្មារតីរដ្ឋធម្មនុញ្ញមាត្រា៤១ ធានាសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ការជួបជុំ និងការបង្កើតសមាគម ដោយមិនរំលោភសិទ្ធិអ្នកដទៃ និងសណ្តាប់ធ្នាប់សាធារណៈ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា២០ សិទ្ធិមានសេរីភាពជួបជុំដោយសន្តិវិធី និងសមាគម និងកាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា២១ ការទទួលស្គាល់សិទ្ធិជួបជុំដោយសន្តិវិធី។

## ២. បាតុកម្ម និង កូដកម្ម៖

១៥%គឺជាអាជ្ញាធរមូលដ្ឋានចាំឃ្លាំមើលជុំវិញសកម្មភាពបាតុកម្ម-កូដកម្ម តាំងពីដើមរហូតដល់ចប់ បើធៀបចំនួនបាតុករ-កូដករសរុប ៩,៧៧១នាក់(ស្ត្រី៥,២០៥នាក់)។ ៨៩%(២៥) នៃបាតុកម្ម កូដកម្មទាំង២៨លើក ត្រូវបានរៀបចំធ្វើឡើងដោយកម្មករសហជិព ក្នុងគោលបំណងស្នើសុំឲ្យដោះស្រាយបញ្ហាប្រាក់ខែ និងទាមទារឲ្យដោះលែងតំណាងកម្មករ។

**ច្បាប់ពាក់ព័ន្ធបាតុកម្មដោយសន្តិវិធី**

- មាត្រា៣៧ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ សិទ្ធិធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី
- មាត្រា៤ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី
- មាត្រា៣១៨ ច្បាប់ស្តីពីការងារ ការធ្វើបាតុកម្ម-ឡុកអៅ

ការធ្វើបាតុកម្ម-កូដកម្ម របស់សហជិពកម្មករ ដោយប្រើសកម្មភាពឈរលើកបដា និងស្រែកស្នើសុំ និងការហែរក្បួនដាក់ញាត្តិ អមដោយអាជ្ញាធរមានសមត្ថកិច្ចខ្លះក្នុងសម្លៀកបំពាក់ឯកសណ្ឋាន និងខ្លះសម្លៀកបំពាក់ស៊ីវិល ហែរហមឈរឃ្លាំមើលព្រោងព្រាតតាមដងផ្លូវនិងទីកន្លែងធ្វើបាតុកម្ម-កូដកម្ម។

អាជ្ញាធរមានកាតព្វកិច្ចសម្របសម្រួល និងការពារសុវត្ថិភាពអ្នកចូលរួម។ យោងច្បាប់ព្រះរាជាណាចក្រកម្ពុជាបានធានាសិទ្ធិកម្មករនិយោជិតក្នុងការធ្វើកូដកម្ម-កូដកម្ម ក្នុងគោលបំណងការពារប្រយោជន៍វិជ្ជាជីវៈ។ ការតវ៉ាទាមទារដោះស្រាយបញ្ហាប្រាក់បៀវត្សន៍ និងស្នើសុំដោះលែងតំណាងរបស់ខ្លួន ជាប្រធានបទស្ថិតក្នុងវិស័យការងារ និងសិទ្ធិសហជីព។ តាមអង្គហេតុ បាតុកម្ម/កូដកម្មធ្វើឡើងតាមរយៈការលើកបដា ស្រែកស្នើសុំ និងហែរក្បួនដាក់ញត្តិ ដែលជាទម្រង់សន្តិវិធី។ ដូច្នេះ សកម្មភាពទាំងនេះស្ថិតក្រោមការការពារដោយរដ្ឋធម្មនុញ្ញ ច្បាប់ការងារ និងច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។ ហើយវត្តមានអាជ្ញាធរអាចមានគោលបំណងក្នុងការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ តែទោះជាយ៉ាងណា តាមគោលការណ៍នីតិរដ្ឋ ការឃ្លាំមើលរបស់អាជ្ញាធរ ត្រូវមានមូលដ្ឋានច្បាប់ច្បាស់លាស់ មានគោលបំណងស្របច្បាប់គឺដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈពិតៗ និងត្រូវសមាមាត្រនឹងចំនួនអ្នកចូលរួមធ្វើបាតុកម្ម ដូច្នោះការឈរឃ្លាំមើលព្រោងព្រាតរបស់អាជ្ញាធរទាំងក្នុងសម្លៀកបំពាក់ឯសណ្ឋាននិងទាំងកម្លាំងសម្លៀកបំពាក់ស៊ីវិល គឺអាចជាទម្រង់បង្កឲ្យមានការភ័យខ្លាច ឬបង្ហាញពីការរឹតត្បិត-ការគំរាមកំហែង ដែលនាំឲ្យប៉ះពាល់ដល់សេរីភាពបាតុកម្ម និងជាឥទ្ធិពលបង្កឲ្យមានការភ័យខ្លាចដល់អ្នកចូលរួមបាតុកម្ម។

## ៣. ការទទួលបានយុត្តិធម៌តាមរយៈប្រព័ន្ធតុលាការ (ការឃ្លាំមើលសវនាការ)

ឆ្នាំ២០២៥ សមាគមអាដហុកបានចូលរួមឃ្លាំមើលសវនាការ ៧១ករណី[5] នៅសាលាដំបូងរាជធានីភ្នំពេញ និងសាលាដំបូងតាមបណ្តារខេត្តចំនួន៨ផ្សេងទៀត។ ក្នុងចំណោម៧១ករណី មានបទឧក្រិដ្ឋចំនួន៤១ករណី និងបទមជ្ឈឹមចំនួន៣០ករណី ដែលមានជនជាប់ចោទ/ចុងចម្លើយជា ជនរងគ្រោះសរុបចំនួន២២៧នាក់ (ស្ត្រី៣៧នាក់-អនីតិជន១៧នាក់) និងដើមបណ្តឹងជាជនរងគ្រោះសរុបចំនួន៣៧នាក់(ស្ត្រី៣៥នាក់-កុមារ០២នាក់)។ ២៧%(១៩ករណី) ត្រូវបានតុលា ការចោទប្រកាន់ពីបទញុះញង់។

---

[5] ៧១ករណីដែលសមាគមអាហុកចូលរួមឃ្លាំមើល គឺជាករណីថ្មី-ករណីបន្តពីឆ្នាំ២០២៤ ដែលសមាគមបានផ្តល់មេធាវីតំណាងផ្លូវច្បាប់។

**ការពន្យាពេលសវនាការនិងសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស៖** របាយការណ៍បង្ហាញថា ២១%(១៥ករណី) នៃករណីដែលសមាគមអាដហុកបានចូលរួមឃ្លាំមើល ត្រូវបានលើកពេលសវនាការ ដោយមិនបញ្ជាក់ថ្ងៃច្បាស់លាស់ ក្រោមមូលហេតុដូចជា ចៅក្រម ឬតំណាងអយ្យការរវល់ និងខ្វះអវត្តមានមេធាវីតំណាងផ្លូវច្បាប់។ សិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងសមស្រប ត្រូវបានធានាដូចមានចែងក្នុងមាត្រា១៤ នៃ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញមាត្រា៣១។ ការលើកពេលសវនាការដោយមិនកំណត់ថ្ងៃ និងការយឺតយ៉ាវអាចប៉ះពាល់ដល់គោលការណ៍ការ ជំនុំជម្រះដោយឆាប់រហ័ស និងសមភាពចំពោះមុខច្បាប់ ហើយបង្កឲ្យមានការខាតបង់ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌។

**ការឃុំខ្លួនលើសនីតិវិធី:** មាន១៨%(១៣ករណី) ត្រូវបានការឃុំខ្លួនបណ្តោះអាសន្នលើសពី៩ខែ រហូតដល់១៣ខែ។ ម្យ៉ាងទៀត ការឃុំខ្លួនលើសកំណត់ ឬគ្មានការពន្យល់ច្បាស់លាស់ អាចបង្កជាការរំលោភលើសិទ្ធិសេរីភាពផ្ទាល់ខ្លួន និងគោលការណ៍សន្មតជាមុនថាគ្មានទោស ដូចមានចែងក្នុងមាត្រា២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នត្រូវអនុវត្តក្នុងកម្រិតកំណត់ និងជាជម្រើសចុងក្រោយ និងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩ ក៏បានកំណត់ថា ការឃុំខ្លួនមុនសវនាការ មិនគួរជាការអនុវត្តជាទូទៅឡើយ ហើយត្រូវមានការត្រួតពិនិត្យដោយតុលាការយ៉ាងទៀងទាត់។

**ពេលវេលាបើកសវនាការយឺតជាងពេលវេលាកំណត់ក្នុងដីកាកោះ** មាន ៩៨%(៧០ករណី) ពេលចាប់ផ្តើសវនាការពិតប្រាកដ យឺតជាងពេលវេលាកំណត់ក្នុងដីកាកោះហៅ យ៉ាងតិចចន្លោះពីជាងមួយម៉ោងទៅជាងពីរម៉ោង។ឧទាហរណ៍ដូចជា បើម៉ោងក្នុងដីកាកំណត់ថា សវនាការជំនុំជម្រះចាប់ផ្តើមនៅម៉ោង០៨:០០ព្រឹក ជាកំហិតតែម៉ោងចាប់ផ្តើមសវនាការជំនុំជម្រះជាក់ស្តែង អាចចាប់ផ្តើមម៉ោង០៩:៣០នាទីឬពេលខ្លះអាចយឺតរហូតដល់ម៉ោងជាង១០:០០ព្រឹក។ បើតាមការឃ្លាំមើលសកម្មភាពយឺតនេះ បានកើតមានដដែលៗជាបន្តបន្ទាប់ ដូចមានបង្ហាញនៅក្នុងរបាយការណ៍ឆ្នាំ២០២៣ និងឆ្នាំ២០២៤។

ការកំណត់កាលបរិច្ឆេទ និងម៉ោងក្នុងដីកាកោះ គឺជាផ្នែកមួយនៃនីតិវិធីផ្លូវច្បាប់ ដែលមានគោលបំណងធានា ភាពប្រកដប្រជានៃនីតិវិធី ធានាការរៀបចំការការពារតាមផ្លូវច្បាប់របស់ភាគី និងធានាការគោរពសិទ្ធិទទួលបានយុត្តិធម៌ទាន់ពេលវេលា។ សកម្មភាពយឺតយ៉ាវ ដែលកើតឡើងជាញឹកញាប់ អាចបង្កផលប៉ះពាល់សិទ្ធិរបស់ភាគីជាពិសេសជនជាប់ចោទដែលកំពុងឃុំខ្លួនបណ្តោះអាសន្ន ជនរងគ្រោះ និងសាក្សីដែលត្រូវចំណាយពេលវេលា និងថវិកាមកចូលរួមក្នុងសវនាការ និងប៉ះពាល់ដល់មេធាវីដែលបានរៀបចំកាលវិភាគការពារផ្សេងៗទៀត។ ដូច្នេះ ប្រសិនបើគ្មានវិធានការកែលំអរ ផ្នែកការគ្រប់គ្រងតុលាការ និងការធានាប្រសិទ្ធភាពនៃដំណើរការយុត្តិធម៌ នាំឲ្យអាចប៉ះពាល់ធ្ងន់ធ្ងរដល់ទំនុកចិត្តសាធារណៈ ប៉ះពាល់លើប្រព័ន្ធតុលាការ ប៉ះពាល់ការគ្រប់គ្រងសវនាការដោយគ្មានប្រសិទ្ធភាព និងប៉ះពាល់ដល់សិទ្ធិចូលរួមដំណើរការរកយុទ្ធិធម៌ ជាពិសេសផ្ទុយស្មារតីមាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១។

**ឧបស័គ្គមេធាវីក្នុងការសិក្សាសំណុំរឿង៖** ៩០% នៃករណីដែលមានការពាក់ព័ន្ធបញ្ហានយោបាយ និងជម្លោះដីធ្លីធំៗ មានការតឹងរឹងក្នុងការអនុញ្ញាតឲ្យ មេធាវីថតចម្លងសំណុំរឿងពេញលេញ ក្រោមមូលហេតុ:ចៅក្រមឬព្រះរាជអាជ្ញាមិនទាន់បានពិនិត្យ ឬមិនទាន់បានចុះហត្ថលេខា ឬជារឿងសម្ងាត់ ឬត្រូវសុំការអនុញ្ញាតពីថ្នាក់លើជាមុនសិន(សួរមេ)។

ការបង្ករការឃើតយ៉ាវដល់មេធាវីក្នុងដំណើរការទទួលបានសំណុំរឿង អាចប៉ះពាល់ដល់គោលការណ៍សិទ្ធិទទួលបានការការពារយ៉ាងមានប្រសិទ្ធភាព។ មាត្រា១៤(3b) កាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបាន ធានាសិទ្ធិឲ្យជនជាប់ចោទមានពេលវេលា និងសម្ភារៈគ្រប់គ្រាន់សម្រាប់រៀបចំការពារ។ ម្យ៉ាងទៀតតាមគោលការណ៍ស្តីពីតួនាទីមេធាវីរបស់អង្គការសហប្រជាជាតិ ក៏បានបញ្ជាក់ថា មេធាវីត្រូវអាចចូលប្រើឯកសារនិងព័ត៌មានចាំបាច់ទាំងអស់ដោយមិនមានការរាំងខ្ទប់មិនសមហេតុផល។

## ៤. ការគំរាមកំហែង និង ការរើសអើងសកម្មជននយោបាយ

យោងតាមរបាយការណ៍ ករណីគំរាមកំហែង និងការរើសអើងសកម្មជននយោបាយ ចំនួន៣៥ករណីដែលភាគច្រើនកើតមាននៅខេត្តកំពង់ចាម(១៣ករណី) និងនៅខេត្តផ្សេងៗទៀតរួមមានកំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ឧត្តរមានជ័យ ពោធិសាត់ សៀមរាប តាកែវ និងភ្នំពេញ។ ក្នុងចំណោម៣៥ករណី៖

- ៦៦%(២៣ករណី) ជាការគំរាមកំហែង ដោយផ្ទាល់ចំពោះសកម្មជននយោបាយ
- ០៨ ករណីកើតឡើងចំពោះសាច់ញាតិសកម្មជនគណបក្សនយោបាយ
- ០៤ ករណីជាការរើសអើងនយោបាយចំពោះអ្នកប្រើប្រាស់បណ្តាញសង្គមដែលរិះគុណគណបក្សនយោបាយ និង/ឬ រដ្ឋាភិបាល។

ការអង្កេតបង្ហាញថា សកម្មភាពគំរាមកំហែងទាំងនោះមានលក្ខណៈស្រដៀងៗគ្នា ក្រោមរូបភាពអាជ្ញាធរមូលដ្ឋានចេញលិខិតអញ្ជើញសមាជិកគណបក្សនយោបាយមួយ ឲ្យមកចូលរួមប្រជុំនៅទីតាំងរដ្ឋបាលមូលដ្ឋាន ប៉ុន្តែបែរជាបញ្ជូនឲ្យទៅជួបនៅស្នាក់ការគណបក្សនយោបាយ ក្នុងលក្ខណៈពិភាក្សាទ្វេភាគី។ នៅក្នុងជំនួបនោះ មានការប្រើប្រាស់វិធីសាស្ត្រ និយាយពាក្យទាក់ទាញផ្លូវអារម្មណ៍ ព្រមទាំងបង្ហាញឯកសារសុំលាលែងពីគណបក្សសាម៉ី និងឯកសារពាក្យសុំចូលរួមជីវភាពនយោបាយជាមួយគណបក្សផ្សេង។ ក្នុងករណីដែលមិនទទួលបានផលល្អ(មិនព្រម) មានការប្រើប្រាស់ពាក្យគំរាមកំហែងដូចជា បើមិនលាលែងពីបក្សសាម៉ី ហើយចុះចូលជាមួយគណបក្សមួយផ្សេងទៀតទេ អាចនឹងបង្កផលប៉ះពាល់ផ្ទាល់ខ្លួន។ ប្រសិនបើនិយាយប៉ុណ្ណឹងហើយ នៅតែមិនបានផល(មិនយល់ព្រម) នោះនឹងអាចឈានទៅដល់មានការ ចាប់ឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នដែលភាគច្រើនចោទពីបទញុះញង់តាមមាត្រា៤៩៤ និង៤៩៥នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។ មានចំនួន១០ករណី ត្រូវបានចាប់ឃាត់ខ្លួន-ឃុំខ្លួនបណ្តោះអាសន្ន ហើយករណីខ្លះត្រូវបានដោះលែងវិញក្រោយពីយល់ព្រមតាមលក្ខខណ្ឌ។

**ច្បាប់ជាតិ៖** រដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា មាត្រា៣៥ បានធានាសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ និង មាត្រា៤២សិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយដោយសេរី និងគ្មានការបង្ខំ។ ច្បាប់ស្តីពី គណបក្សនយោ បាយមាត្រា២ ធានាការចូលរួមគណបក្សនយោបាយដោយស្ម័គ្រចិត្តតាមរបបប្រជាធិបតេយ្យសេរីពហុបក្ស ។មាត្រា៧១នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានហាមឃាត់ដាច់ខាតចំពោះសកម្មភាព ដែលរំលោភសេរីភាពបុគ្គល ហាមឃាត់ការបង្ខិតបង្ខំ និងការគម្រាមកំហែងឲ្យបុគ្គលណាម្នាក់ចូលគណបក្សនយោបាយ ឬបោះឆ្នោតឲ្យគណបក្សណាមួយ។

**ច្បាប់អន្តរជាតិ៖** មាត្រា២២ សេរីភាពសមាគម និងការចូលរួមនយោបាយ នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា២០ សិទ្ធិសមាគម និងជួបជុំដោយសន្តិវិធី នៃចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

បើពិនិត្យច្បាប់ជាតិ និងច្បាប់អន្តរជាតិ ការបង្ខិតបង្ខំ ឬការគំរាមកំហែងឲ្យលាលែង ឬឲ្យចូលរួមជាមួយសមាគម ឬគណបក្សនយោបាយណាមួយ ដែលមិនស្របនឹងឆន្ទៈ ត្រូវបានចាត់ទុកថា ជាការរំលោភសិទ្ធិនយោបាយ និងសេរីភាពសមាគម។ ជាពិសេសសកម្មភាព "ការប្រើប្រាស់យន្តការរដ្ឋក្នុងគោលបំណងនយោបាយ ការប្រើប្រាស់បទចោទព្រហ្មទណ្ឌដើម្បីបង្កការភ័យខ្លាច លក្ខខណ្ឌដោះលែង ដែលអាចប៉ះពាល់ដល់សេរីភាពនយោបាយ និងការដាក់សម្ពាធលើសេរីភាពនយោបាយ និងសមាគម" អាចមិនស្របតាមកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព ការពារ និងបំពេញសិទ្ធិមនុស្ស។

ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់បោះឆ្នោត បានធានាសិទ្ធិសេរីភាពពលរដ្ឋក្នុងការបង្កើត ចូលរួម និងជ្រើសរើសគណបក្សដែលខ្លួនពេញចិត្តដោយស្ម័គ្រចិត្ត ហើយច្បាប់នេះ ហាមឃាត់ដាច់ខាតនូវរាល់សកម្មភាពបង្ខិតបង្ខំ គម្រាមកំហែង ឬបំបិទសិទ្ធិសេរីភាពក្នុងការសម្រេចចិត្តនយោបាយរបស់បុគ្គល ហើយធានាការប្រកួតប្រជែងដោយសេរី និងយុត្តិធម៌ ប្រជាពលរដ្ឋមានស្វ័យភាពក្នុងការបង្កើតឬចូលរួមគណបក្សនយោបាយស្របតាមឆន្ទៈនិងជំនឿរបស់ខ្លួន។

ការប្រើប្រាស់អំណាចដើម្បីបង្ខំ និងគម្រាមកំហែងសមាជិកគណបក្សនយោបាយណាមួយ ត្រូវបានចាត់ទុកជាការរំលោភសិទ្ធិសេរីភាពនយោបាយដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធជាពិសេសមាត្រា៧១នៃច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រ បានហាមឃាត់ដាច់ខាតចំពោះ"ជនណាដែលប្រើប្រាស់មធ្យោបាយ "បង្ខិតបង្ខំ គំរាមកំហែង បំភិតបំភ័យ ឬទិញទឹកចិត្ត" ដើម្បីឱ្យបុគ្គលម្នាក់ទៀតចូលជាសមាជិកគណបក្សនយោបាយ ឬបោះឆ្នោតឱ្យគណបក្សណាមួយ គឺជាអំពើខុសច្បាប់" ដែលអាចប្រឈមមុខនឹង ទោសបញ្ញត្តិជំពូកទី១០ នៃច្បាប់នេះ។

ដូច្នោះដើម្បីធានាការអនុវត្តច្បាប់ស្របតាមគោលការណ៍នីតិរដ្ឋគួរតែះ មានការធាននានូវឯករាជ្យភាព និងអព្យាក្រឹតភាពនៃអាជ្ញាធរ និងការពារសកម្មជននយោបាយ ពីការគំរាមកំហែងនិងការរើសអើងផ្សេងៗ។

### ៥. ការគំរាមកំហែងសកម្មជនសិទ្ធិមនុស្ស

របាយការណ៍បង្ហាញថា មានករណីគំរាមកំហែងលើសកម្មជនសកម្មជនសិទ្ធិមនុស្សចំនួន២១ករណី ដែលភាគច្រើនធ្វើឡើងដោយសកម្មជនគណបក្សនយោបាយ បន្ទាប់ពីសកម្មជនសិទ្ធិមនុស្សបានបង្ហោះសារ នៅលើបណ្តាញសង្គម (ហ្វេសប៊ុក) ជាពិសេសរឿងវិវាទព្រំដែន ក្នុងចំណោមករណីនេះមានៈ

- ០៧ករណី(៣៣%) ត្រូវបានចាប់ឃុំខ្លួនបណ្តោះអាសន្ន
- ០២ករណី រត់គេចខ្លួនដោយភ័យខ្លាច

ការគំរាមកំហែងនេះ មានគោលបំណងបំបាក់ស្មារតី និងបង្ហាញឲ្យឃើញពីការដាក់សម្ពាធលើសកម្មជនសិទ្ធិមនុស្ស ក្នុងការប្រើប្រាស់សិទ្ធិសេរីភាពបញ្ចេញមតិតាមបណ្តាញសង្គម។ ជាពិសេស ករណីឃុំខ្លួនបណ្តោះអាសន្នមួយចំនួន ត្រូវបានដោះលែងក្រោមលក្ខខណ្ឌឲ្យធ្វើកិច្ចសន្យាទទួលកំហុស ឬ បង្ហោះវីដេអូសុំទោសជាសាធារណៈ និងបញ្ឈប់សកម្មភាពរិះគុណរដ្ឋាភិបាល តាមបណ្តាញសង្គម។ ការដោះលែង ដោយមានលក្ខខណ្ឌអាចមិនស្របតាមគោលការណ៍ច្បាប់ "សិទ្ធិមិនត្រូវបង្ខំឲ្យសារភាព ឬធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង " ការនេះធ្វើឲ្យសាធារណៈជនមានការសង្ស័យថាជាការដាក់សម្ពាធជាជាងការសុំទោសទទួលកំហុសចេញពីឆន្ទៈដោយស្ម័គ្រចិត្ត។

ការចាប់ឃុំខ្លួន ឬដាក់សម្ពាធ ដោយសារការបញ្ចេញមតិបង្ហោះសារលើបណ្តាញសង្គមដោយមិនមានភស្តុតាងបញ្ជាក់ពីបទល្មើសពិតប្រាកដ ដែលប៉ះពាល់ដល់សន្តិសុខជាតិ និង/ឬ សណ្តាប់ធ្នាប់សាធារណៈ អាចត្រូវបានចាត់ទុកថាជាការ

រំលោភលើសិទ្ធិសេរីភាពបញ្ចេញមតិ ដែលធានាដោយរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា៤១, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមាត្រា១៩ និង កាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩។

ការអនុវត្តបែបនេះ អាចបង្កផលប៉ះពាល់អវិជ្ជមានលើបរិយាកាសសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។ ដូច្នេះ គួរតែមានការពិនិត្យឡើងវិញនីតិវិធី និងការអនុវត្តច្បាប់ ដើម្បីធានាថាការកំណត់សិទ្ធិណាមួយ ត្រូវស្របតាមគោលការណ៍ច្បាប់ជាតិ និងស្តង់ដារអន្តរជាតិ ដែលកម្ពុជា បានទទួលស្គាល់។

ការដោះលែងដោយមានលក្ខខណ្ឌ ឲ្យចុះហត្ថលេខា (ផ្តិតមេដៃ) សុំទោស និងទទួលកំហុស ប្រសិនបើធ្វើឡើងក្រោមសម្ពាធ ឬការគំរាមកំហែងអាចផ្ទុយនឹងគោលការណ៍នីតិរដ្ឋ និងសិទ្ធិដំណើរការតុលាការយុត្តិធម៌ ជាពិសេសផ្ទុយស្មារតីមាត្រា១៤(3-g)នៃកាតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានកំណត់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌និងសិទ្ធិមិនត្រូវបង្ខំឲ្យសារភាពប្រឆាំងខ្លួនឯង។ បន្ថែមពីនេះ ការដាក់លក្ខខណ្ឌបញ្ឈប់ការរិះគន់រដ្ឋាភិបាល អាចត្រូវបានចាត់ទុកថា ជាការកំណត់សិទ្ធិសេរីភាពបញ្ចេញមតិ លើសពីកម្រិតដែលច្បាប់អនុញ្ញាត។

សេចក្តីប្រកាសជាសកលស្តីពីអ្នកការពារសិទ្ធិមនុស្ស បានបញ្ជាក់ថា បុគ្គលមានសិទ្ធិលើកកម្ពស់ និងការពារសិទ្ធិមនុស្សដោយសេរី ហើយរដ្ឋមានកាតព្វកិច្ចការពារពី ការគំរាមកំហែង ការបង្ខិតបង្ខំ និងការប្រឆាំង។ ក្នុងករណីដែលសកម្មជនត្រូវបានគំរាមកំហែង ឃុំខ្លួន ឬបង្ខំឲ្យបញ្ឈប់សកម្មភាព ដោយសារការប្រើប្រាស់សិទ្ធិស្របច្បាប់ នោះអាចត្រូវបានចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋ។

### ៦. ការធ្វើទារុណកម្ម

របាយការណ៍បង្ហាញថា មានករណីទារុណកម្មចំនួន ២៦ករណី កើតឡើងក្នុងអំឡុងពេលសួរចម្លើយនៅក្នុងបន្ទប់នៃប៉ុស្តិ៍រដ្ឋបាលឃុំ/សង្កាត់ អធិការស្រុក/ខណ្ឌ និងកងរាជអាវុធហត្ថស្រុក/ខណ្ឌ។ ក្នុងគោលបំណងសួរយកចម្លើយ មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថ បានប្រើអំពើហិង្សា បង្ខំឲ្យជនសង្ស័យ "ប្រើប្រាស់គ្រឿងញៀន និងក្មេងទំនើង" ដោយប្រើវិធីសាស្ត្រផ្សេងៗដូចជា: វាយដោយដៃ ទាត់ជាក់ដោយជើង ទាំងដៃជនសង្ស័យកំពុងជាប់ខ្នោះ។ ការប្រើអំពើហិង្សានេះបានបណ្តាលឲ្យជនសង្ស័យ មិនអាចទ្រាំនឹងការឈឺចាប់បានហើយ ត្រូវបង្ខំឲ្យសារភាព និងផ្តិតស្នាមមេដៃលើកំណត់ហេតុសួរចម្លើយទោះបីជាមិនមានឆន្ទៈស្ម័គ្រចិត្តក៏ដោយ។ ការប្រើអំពើហឹង្សានេះ បានបន្សល់ទុកនូវស្នាមជាំ និងរបួសលើរាងកាយជនសង្ស័យ។

បន្ទាប់ពី ទទួលបានការសារភាពតាមគោលបំណងរបស់ខ្លួន មន្ត្រីទទួលបន្ទុកបានរៀបចំសំណុំឯកសារបញ្ជូនទៅតុលាការ។ ទន្ទឹមនេះ ជនត្រូវចោទទាំងនោះ មិនហ៊ានដាក់ពាក្យបណ្តឹងប្រឆាំងនឹងអំពើទារុណកម្មលើរូប រាងកាយបង្ខំឲ្យសារភាព ទទួលកំហុសផ្តិតមេដៃលើកំណត់ហេតុសួរចម្លើយឡើយ ដោយភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ខណៈពួកគេកំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងពន្ធនាគារ។

ការប្រើអំពើហិង្សបង្ខិតបង្ខំលើរូបរាងកាយការបង្ខំឲ្យផ្តិតមេដៃលើកំណត់ហេតុសួរចម្លើយគឺជាការរំលោភលើគោលការណ៍ស្ម័គ្រចិត្ត និងនីតិវិធីត្រឹមត្រូវដែលត្រូវបានហាមឃាត់ដាច់ខាត ហើយអំពើទាំងនេះ ផ្ទុយស្មារតីច្បាប់ជាធរមាន៖

**ច្បាប់ជាតិៈ** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣៨ ហាមឃាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តអំពើឃោរឃៅ អំពើ អមនុស្សធម៌ ឬបំបាក់ទឹកចិត្ត។ ការសារភាពដែលបានមកពីការបង្ខំ ឬទារុណកម្ម មិនអាចយកមកប្រើជាភស្តុតាងនៃពិរុទ្ធភាពបានឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣២១កថាខណ្ឌទី៣ ការបង្ខំទាំងផ្លូវកាយនិងផ្លូវចិត្តគឺគ្មានតម្លៃជាភស្តុតាង ឡើយ។

**ច្បាប់អន្តរជាតិៈ** អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តអំពើឃោឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកកិត្តិយស មាត្រា១ និយមន័យអំពើទារុណកម្ម មាត្រា២ មិនមានកាលៈទេសៈពិសេសណាមួយ អាចយកមកធ្វើជាមូលហេតុសម្រួលទោសចំពោះទារុណកម្មបានឡើយ និងមាត្រា៥កំណត់ថាការសារភាពដែលបានមកពីទារុណកម្មមិនអាចប្រើជាភស្តុតាងឡើយជាពិសេសការប្រើអំពើហិង្សា ក្នុងគោលបំណងបង្ខំឲ្យសារភាព ប្រព្រឹត្តដោយមន្ត្រីសាធារណៈ។ កាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៧ ហាមឃាតការធ្វើទារុណកម្ម។

ជនរងគ្រោះមិនហ៊ានដាក់ពាក្យបណ្ដឹងប្រឆាំងអំពើទារុណកម្ម បង្ខំឲ្យសារភាពទទួលកំហុស ផ្តិតស្នាមមេដៃលើកំណត់ហេតុសួរចម្លើយនៅតំណាក់ការនគរបាលយុត្តិធម៌ គឺបង្ហាញឲ្យឃើញភាពឯករាជ្យនៃប្រព័ន្ធយុត្តិធម៌ចាប់តាំងពីនៅនគរបាលយុត្តិធម៌។

យោងគោលការណ៍ស្ម័គ្រចិត្ត ជនសង្ស័យ/ជនល្មើស មានសិទ្ធិសុំមិនឆ្លើយ ឬឆ្លើយដោយសេរី ដោយគ្មានការគំរាមកំហែង និងមានសិទ្ធិមានមេធាវី។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចប្រើហិង្សា បង្ខំឱ្យជនសង្ស័យយល់ព្រមទទួលកំហុសផ្តិតមេដៃលើសេចក្តីសន្និដ្ឋាន ឬ កំណត់ហេតុសួរចម្លើយ ក្រៅពីឆន្ទៈស្ម័គ្រចិត្ត ពិតប្រាកដបាន ឡើយ។ដូច្នេះកំណត់ហេតុដែលផ្តិតមេដៃដោយការបង្ខំ ដោយប្រើអំពើហិង្សា មិនអាចយកមកប្រើប្រាស់ជាភស្តុតាងដាក់បន្ទុកក្នុងសវនាការបានឡើយ (និរាករណ៍) ជាពិសេសត្រូវផ្តន្ទាទោសអ្នកប្រព្រឹត្តអំពើហិង្សបង្ខំឲ្យសារភាពទទួលកំហុសតាមច្បាប់ជាធរមាន។

## ៧. ការចាប់ឃាត់ខ្លួន និងការឃុំខ្លួនសកម្មជនៈ

យោងរបាយការណ៍ឃ្លាំមើលឆ្នាំ២០២៥ មានការចាប់ឃាត់ខ្លួននិងឃុំខ្លួនសរុបចំនួន ៨៧ករណី(មនុស្ស៨៧នាក់-ក្នុងនោះស្ត្រី ០៣នាក់) ដែលផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះ១៨ខែ ទៅ ៦ឆ្នាំជាង។ ក្នុងនោះ ៤១ករណី ត្រូវបានចោទប្រកាន់ពីបទ "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តាមមាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា" ដោយសារការបញ្ចេញមតិតាមបណ្តាញសង្គម (ហ្វេសប៊ុក) អំពីភាពអសកម្មរបស់រដ្ឋាភិបាលអំពីបញ្ហាជម្លោះព្រំដែន អំពីសេចក្តីព្រាងច្បាប់ដកសញ្ជាតិ អំពីបញ្ហាផ្តល់ប័ណ្ណក្រីក្រ និង អំពីករណីចាប់ជំរិត(Scame)នៅកម្ពុជា។ មានមួយករណីត្រូវបានដោះលែង បន្ទាប់ពីភរិយាជនជាប់ចោទ បានចេញវីដេអូសុំទោសជាសាធារណៈ។ ក្នុងចំណោម ៨៧ករណី រួមមានៈ

- ៤០ករណី ជាសកម្មជននយោបាយមកពីគណបក្សដែលមានមតិផ្ទុយចំនួន៨គណបក្ស
- ១៩ករណី ជាប្រជាពលរដ្ឋសកម្មបញ្ចេញមតិតាមបណ្តាញសង្គម
- ១២ករណី ជាអ្នកសារព័ត៌មាន
- ០២ករណី ជាព្រះសង្ឃ
- ០២ករណី ជាអ្នកការពារសិទ្ធិមនុស្ស
- ០១ករណី ជាថ្នាក់ដឹកនាំសហជិត
- ០១ករណី ជាអ្នកវិភាគ

ការដាក់កម្រិតលើសិទ្ធិសេរីភាពបញ្ចេញមតិត្រូវតែៈ មានមូលដ្ឋានច្បាប់ច្បាស់លាស់ មានសមាមាត្រ និងមានភាពចាំបាច់ ប្រសិនបើ មានភស្តុតាងជាក់ស្តែងអាចនឹងកើតមានបទឧក្រិដ្ឋ ឬ អំពើហិង្សា ដែលនាំឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និង សណ្តាប់ធ្នាប់សាធារណៈ ឬសិទ្ធិអ្នកដទៃ។ បើមិនដូច្នោះ ការដាក់កម្រិតសិទ្ធិសេរីភាពមញ្ចេញមតិផ្ទុយស្មារតីរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាមាត្រា៤១ ធានាសិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាននិងសេរីភាពប្រមូលផ្តុំ និងច្បាប់អន្តរជាតិ មាត្រា១៩ នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលធានា សេរីភាពបញ្ចេញមតិ ព្រមទាំងសេចក្តីពន្យល់លេខ៣៤ នៃអង្គការសហប្រជាជាតិ។

ការប្រើប្រាស់មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសលើការបញ្ចេញមតិរិះគន់រដ្ឋាភិបាល និងបញ្ហាកើតមានក្នុងសង្គម ត្រូវបានអ្នកជំនាញអន្តរជាតយល់ថាការបកស្រាយ លើការចោទប្រកាន់នេះមានលក្ខណៈទូលំទូលាយ ដែលអាចប៉ះពាល់ដល់គោលការណ៍ច្បាប់ច្បាស់លាស់។ ការចាប់ឃុំខ្លួនដោយសារការបញ្ចេញមតិសន្តិវិធី អាចត្រូវបានចាត់ទុកថាជាការឃុំខ្លួនដោយមិនសមស្រប តាមការបកស្រាយរបស់ក្រុមការងារសហប្រជាជាតិ ដូចមានចែងក្នុងមាត្រា៩ នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការចាប់ឃុំខ្លួនដោយបំពាន។

អង្គការសហប្រជាជាតិបានទទួលស្គាល់តួនាទីសំខាន់របស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ក្នុងសង្គមប្រជាធិបតេយ្យ។ ការចាប់ឃុំខ្លួនក្រុមនេះដោយសារការបំពេញតួនាទីវិជ្ជាជីវៈ ការបញ្ចេញមតិ អាចជាការរំលោភលើកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋ រួមមានៈ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមាត្រា១ សិទ្ធិលើកម្ពស់ និងការពារសិទ្ធិមនុស្ស និងមាត្រា១២ក ឋាខណ្ឌទី២ រដ្ឋត្រូវធានាការពារអ្នកការពារសិទ្ធិមនុស្សពីអំពើហិង្សា ការគំរាមកំហែង ការសងសឹក ឬការចាប់ខ្លួនដោយបំពាន។

## III. សេចក្តីសន្និដ្ឋាន

ឆ្នាំ២០២៥ របាយការណ៍ឃ្លាំមើលករណីសិទ្ធិមនុស្សបានបង្ហាញថាៈ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា កំពុងនៅបន្តប្រឈមនឹងនិន្នាការរឹតត្បិតខ្លាំងលើសេរីភាពមូលដ្ឋាន សិទ្ធិនយោបាយ និង សិទ្ធិទទួលបានយុត្តិធម៌។ ការប្រើប្រាស់បទចោទព្រហ្មទណ្ឌ ជាពិសេសបទ "ញុះញង់" ដើម្បីដាក់សម្ពាធលើការបញ្ចេញមតិរិះគន់ ការរឹតត្បិតសេរីភាពជួបជុំដោយសន្តិវិធី ការគំរាមកំហែងសកម្មជន និងការធ្វើទារុណកម្ម ក្នុងដំណាក់កាលសួរចម្លើយ មានលក្ខណៈស្រដៀងៗគ្នា ដែលអាចប៉ះពាល់ដល់គោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។

ក្នុងចំណោមករណីរំលោភសិទ្ធិមនុស្សចំនួន ២១៥ ករណី មានជនរងគ្រោះដោយផ្ទាល់ ១៥,០៣៩ នាក់ (ស្ត្រី ៥០.៣%) ដែលភាគច្រើនជាប្រជាពលរដ្ឋមានជីវភាពក្រីក្រ និងជំពាក់បំណុល។ ការរឹតត្បិតភាគច្រើនផ្តោតលើសកម្មជននយោបាយ និង សកម្មជនសង្គម រួមមានអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន សហជីព និងយុវជនដែលប្រើប្រាស់បណ្តាញសង្គមក្នុងការបញ្ចេញមតិ។

ទន្ទឹមនឹងនេះ ទិន្នន័យឃ្លាំមើលសវនាការ បង្ហាញពីបញ្ហាសំខាន់ៗក្នុងប្រព័ន្ធយុត្តិធម៌ រួមមានការឃុំខ្លួនបណ្តោះអាសន្នលើសកំណត់ ការលើកពេលសវនាការជាបន្តបន្ទាប់ និងឧបសគ្គក្នុងការចូលប្រើសំណុំរឿងរបស់មេធាវី ដែលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាមួយគ្នានេះ ការភ័យខ្លាច និងការខ្វះទំនុកចិត្តលើដំណើរការស្វែងរកយុត្តិធម៌ ជាមូលហេតុនាំឲ្យ ៩២% នៃករណីដែលទទួលបានដោយសមាគមអាដហុក ជនរងគ្រោះមិនដាក់ពាក្យបណ្តឹង។

សរុបមក និន្នាការទាំងនេះ បង្កឥទ្ធិពលអវិជ្ជមាន ដល់ការគោរពសិទ្ធិមនុស្ស និងទំនុកចិត្តសាធារណៈលើប្រព័ន្ធយុត្តិធម៌។ ដើម្បីជានាបរិយាកាសសង្គម ដែលគោរពសិទ្ធិសេរីភាព តាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ តម្រូវឲ្យមានការកែទម្រង់ជាប្រព័ន្ធ ការអនុវត្តច្បាប់ដោយស្មើភាព និងការគោរពកាតព្វកិច្ចសិទ្ធិមនុស្ស ស្របតាមរដ្ឋធម្មនុញ្ញ និងស្តង់ដារអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់។

## IV. **អនុសាសន៍**

ដើម្បីចូលរួមលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ក្នុងនាមសមាគមអាដហុក មានអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

### ចំពោះរដ្ឋាភិបាល

1. ពិនិត្យ និងកែសម្រួលការអនុវត្តមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌ ដើម្បីជានាដល់លំហរសេរីភាពបញ្ចេញមតិ និងការជួបជុំប្រមូលផ្តុំដោយសន្តិវិធី ស្របតាមស្មារតី មាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា មាត្រា១៩ និងមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ព្រមទាំង សេចក្តីពន្យល់ទូទៅលេខ៣៤ នៃអង្គការសហប្រជាជាតិ អំពីសេរីភាពនៃគំនិត និងការសម្តែងមតិ ។
2. ពង្រឹងការអនុវត្តសេចក្តីជូនដំណឹងក្រសួងមហាផ្ទៃ លេខ២០០៦ស.ជ.ណ ចុះថ្ងៃទី២៧ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីជានាដល់សកម្មភាពរបស់ សមាគមអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅតាមមូលដ្ឋាន ក្នុងការជួបប្រជុំ បើវគ្គរៀនសូត្រ សិក្ខាសាលា ផ្សេងៗ ដោយមិនមានការរំខាន និងរិតត្បឹត ព្រមជាមួយគ្នានេះ ក៏ត្រូវដាក់វិន័យផងដែរចំពោះអាជ្ញាធរណាដែលមិនអនុវត្ត ឬអនុវត្តផ្ទុយពីខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ។
3. ពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់អំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពីសេសគោលការណ៍សេរីភាពជាមូលដ្ឋាន និងអនុសញ្ញាអន្តរជាតិស្តីពីទារុណកម្ម ដើម្បីជានាចំពោះការអនុវត្តសេរីភាពមូលដ្ឋានរបស់ពលរដ្ឋ និងជានាការសួរចម្លើយធ្វើឡើងដោយស្ម័គ្រចិត្ត មានវត្តមានមេធាវី ព្រមទាំងបង្កើតយន្តការត្រួតពិនិត្យ ទទួលពាក្យបណ្តឹង និងការពារជនរងគ្រោះពីអំពើទារុណកម្មផងដែរ។
4. ធានាសិទ្ធិជំនុំជម្រះឆាប់រហ័ស និងយុត្តិធម៌ កែលម្អការគ្រប់គ្រងសវនាការ ជានាសិទ្ធិមេធាវីចូលប្រើសំណុំរឿងពេញលេញ។

### ចំពោះសហគមន៍អន្តរជាតិ និងដៃគូអភិវឌ្ឍន៍

5. បន្តតាមដាន និងជំរុញការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សតាមយន្តការអង្គការសហប្រជាជាតិ និងគាំទ្រកម្មវិធីពង្រឹងសមត្ថភាពប្រព័ន្ធយុត្តិធម៌ និងការការពារអ្នកការពារសិទ្ធិមនុស្ស។